# សាស្ត្រាក្តាម

១.ព្រហាមផ្គរធ្ងន់ ផ្គរមិនទុរជន នឹងក្តាមឡើយណា
ដូចកលសាច់ញាតិ សន្ដានផងគ្នា ដ្បិតចេញវស្សា
ផ្គរលាក្តាមទៅ។

២.ផ្គរមានមេត្តា ផ្គរផ្តាំក្តាមថា ដ្បិតក្តាមកម្លៅ
ថារឿយអស់ក្តាម ធ្វើរន្ធឱ្យជ្រៅ ខ្លួនឯងកម្លៅ
ជាសត្វតិរច្ឆាន។

៣.ដ្បិតអញនឹងទៅ អញឱ្យហៅចៅ មកប្រាមព្រមាន
ក្រែងអត់នឹងអញ មានភ័យដល់ប្រាណ រិះគិតរកស្ថាន
លំនៅកំបាំង។

៤.រកកៀនរកកោះ កន្លៀតចន្លោះ ប្របខាងត្រពាំង
គិតពីឥឡូវ កុំឱ្យដល់ប្រាំង ក្រែងដីរឹងគាំង
កកាយពុំបាន។

៥.ដ្បិតអញនេះឮ មនុស្សលោកនឹងធ្វើ ក្បាលហាងឯងភាន
ថាវាពិសា អាត្មាឯងមាន ខ្លាញ់ពន់ប្រមាណ
វានឹងដុតធី។

៦.មនុស្សលោកវាថា បុកក្តាមពិសា នឹងអម្ពិលខ្ចី
នឹងស្លឹកសណ្តែក នឹងម្អមលាយថ្មី បុកពុំទាន់ធី
ស្រក់ទឹកមាត់មុន។

៧.មនុស្សខ្លះវាថា ខែចេញវស្សា ក្តាមវែងខ្លាញ់លន់
ទន្ទឹងតែព្រឹក វាដើរគយគន់ បើវាឃើញរន្ធ
វាជីកយកបាន។

៨.ខ្លះរកជញ្ជាត់ វាថាឯងកាត់ ស្រូវវាជាម្តង
ប្រាមប្រាប់កូនចៅ សាច់ញាតិផៅផង កុំឱ្យឃ្មើសឃ្មង
ប្រហែសខ្លួនប្រាណ។

៩.ខ្លួនឯងពាយងាយ ម្តេចហានកកាយ ភ្លឺស្រែជាស្ថាន

លិចទឹកទាល់អស់ ស្រូវលាស់ពុំបាន វានឹងជីកប្រាណ
ជាអាហារវា។

១០.វាយកទៅដុត ខ្លាញ់ឯងរលត់ ទាំងភ្លើងសោះសា
ឆ្អិនស្រេចហើយនៃ មកវែទំពា ក្រៀបក្រួបមហិមា
ដូរនឹងបាយកក។

១១. វាចីខ្លួនឯង វាថាជាល្បែង ឆ្ងាញ់ដូចគេត្បក
បើចីទទេ មិនដូចបាយកក វាចង់ទៅរក
មកដុតចីទៀត។

១២.ចៅឯងរិះរក៏ ត្រពាំងមានថ្ម ចៅយកខ្លួនសៀត
ប្រយ័ត្នឱ្យល្អ ច្រកថ្មចង្អៀត ប្រឋាំងប្របៀត
កុំឱ្យឃើញខ្លួន។

១៣.ចៅមើលមនុស្សលោក វាដើររកឈ្លោក រវៀសរត់ពួន
ឲ្យវាកំបាំង ខាងច្រាំងលាក់ខ្លួន កុំឲ្យវាជួន
វាចាប់យកទៅ។

១៤_ហៅអញអាសូរ ជួយរិះគិតគូរ ប្រាមប្រាប់ប្រដៅ
ដ្បិតផ្គរនឹងក្តាម នូវមនុស្សក្បាលខ្មៅ វាយកក្តាមទៅ
ដុតចីបាយលេង។

១៥_ផ្ដែផ្ដាំស្រេចហើយ ទើបក្ដាមច្លាស់ឆ្លើយ អ្នកអើយសូមទាន
ស្មើអ្នកអាពុក បង្កើតខ្ញុំបាន ស្មើអ្នកធ្វើស្ពាន
ឲ្យខ្ញុំនៅហោង។

១៦.អះអ្នកប្រដៅ អស់អាថិរាក់ជ្រៅ គុណអ្នកមហាថ្លៃ
ឥតអ្វីនឹងសង ម៉្លោះហោងពេកក្រៃ ខ្ញុំចាំពីថ្ងៃ
នេះទៅហោងណា។

១៧.អ្នកអើយអ្នកស្ដាប់ អញខ្ញុំនឹងប្រាប់ ឲ្យអ្នកស្ដាប់វ៉ា
មានកាលមួយថ្ងៃ ខ្ញុំចរយាត្រា ទៅលេងនៅនា
ថ្លុកមួយធំក្រៃ។

១៨.ពើបពះវាដើរ ផងងាសចេញមក៏ ពីព្រៃនោះនៃ
ក្រឡេកឃើញខ្ញុំ លោតច្រំនឹងក្ប័យ តេជះខ្ញុំវៃ

ខ្ញុំវេះរួចហោង។

១៩.ខ្ញុំពួនក្រោមគល់ រកខ្ញុំពុំយល់ វាស្ដាយកន្ទួង
ថាឲ្យក្ដាមធំ ដុតថីបាយម្ដង វាចោរដកទង
ចង់ថីខ្ញុំណាស់។
២០.លុះចាប់ពុំបាន វាដើរទៅស្ពាន ឯទៀតនានា
ចាប់អស់ក្ដាមដាក់ ក្នុងត្រកហើយណា វាចរយាត្រា
ដើរទៅទៀតហោង។
២១.ខ្ញុំមើលទៅយល់ ក្នុងត្រកង់ងុល កង្កែបក្ដាមផង
នៅក្នុងត្រកវា អាត្មាខ្ញុំហោង ក្រែងដូចក្ដាមផង
ខ្ញុំគិតអនិច្ចា។
២២.អ្នកអើយខ្ញុំខ្លាច មនុស្សមានអំណាច រអាមរអា
ត្រង់ខ្វារត្រង់ជីក ខ្ញុំខ្លាចណាស់ណា វាមុតអាត្មា
របើកខ្វាត់ខ្វាយ។
២៣.បើតែខ្ញុំនៅ ធ្វើរន្ធឲ្យជ្រៅ កុំឲ្យឃើញកាយ
ខុសតែកង្កែប ច្រវែបអន្ដរាយ វាមកនៅលាយ
ខូចទាំងជាកាច។
២៤_បើឮភ្លៀងម្ដង វាយំរំពង លោតលេងរសាច
វាសើចវាលេង ចិត្តវាមិនខ្លាច វាអាងអំណាច
អ្វីនៅខ្លួនវា។
២៥.មិនរាងមិនចាល គេធ្វើផៀតហាល ដុតថីពិសា
ខ្លះយកទៅលក់ កាត់ទាំងបាទា ហើយកាត់សិរសា
ទើបវាសំអុះ។
២៦.យកខ្ទឹយកម្រេច បង់ខ្ទឹមបន្តិច ប្រហុកបង់ចុះ
យកស្លឹកសង្រៃ នូវស្ពៃបង់ស្មោះ ហុតឡើងថាឱះ
ពិសាពេកពន់។
២៧.វាថីខ្លួនឯង វាថាជាល្បែង កង្កែបខ្លាញ់ហើយ
ថីណាវាមិន ឆ្អែតឆ្អន់សោះឡើយ វាគិតវាគយ

ដើររកទៀតហោង។

២៨.អ្នកអើយឯខ្ញុំ មានដង្កៀបធំ មិនយកខ្ញុំបាន
ខ្ញុំកៀបដៃជាប់ ចង្រៃសាមាន្យ ឲ្យដំចៅប្រាណ
ពិការជាម្ដង។

២៩. អ្នកអើយឯខ្ញុំ តែងគិតអារម្មណ៍ សព្វថ្ងៃឯងហោង
យល់មនុស្សចង្រៃ ពេកក្រៃកន្លង ខ្ញុំស្អប់ណាស់ហោង
ពេកក្រៃមហិមា។

៣០.ខ្ញុំឃើញវាដើរ ចំអើតភ្នែកមើល ក្រឡេកក្រឡៅ
វាស្រែកហៅគ្នា មកវ៉ាចៅវ៉ៅ យកត្រកមកចៅ
អញនឹងដាក់ក្ដាម។

៣១.ខ្ញុំឮវាថា ក្នុងអង្គអាត្មា ភិតភ័យអស់ប្រាណ
ខ្ញុំរត់ម្នីម្នា ចូលក្នុងរន្ធបាន វាចោរសាមាន្យ
រកខ្ញុំពុំយល់។

៣២.ប្រសិនតែឃើញ វាយកទៅធី អស់អង្គអាត្មា
ភ័ព្វមានខ្ញុំចេះ តម្រិះខ្ញុំណា គេចវេះចេញវ៉ា
ខ្ញុំរួចម្ល៉េះហោង។

៣៣.រីឯមនុស្សសព្វថ្ងៃ គ្មានបច្ច័យនឹងសីលទាន
ទៅបរលោកនាយគ្មាន នោះសឹងសាប់សូន្យជាម្ដង។

៣៤.បើបានសីលនិងទាន នោះសឹងមានឧបនិស្ស័យ
ទៅបរលោកនោះនៃ ពុំលែងឡើយសឹងរាល់គ្នា។

៣៥.ពាក្យនេះខ្ញុំលើកលង ខ្ញុំលើកល្បងតាមប្រាជ្ញា
កុំឲ្យសន្តានថា ខ្ញុំលើកលងទៅឯងហោង។

៣៦.ខ្ញុំលែងលើកហើយ។